Government of Western Australia
North Metropolitan Health Service

BreastScreen WA
WA's only accredited screening service

# បន្ទាប់ពីអាយុ៧៥ឆ្នាំ ... តើខ្ញុំគួរបញ្ឈប់ ឬខ្ញុំគួរបន្តការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស?

## នេះគឺជាព័ត៌មានខ្លះៗដើម្បីជួយអ្នកធ្វើការសម្រេចថាតើគួរបញ្ឈប់ ឬបន្តការថតពិនិត្យដោះ។

- មានភ័ស្តុតាងនៃអត្ថប្រយោជន៍ទូទៅសម្រាប់ស្ត្រីដែលមានអាយុ៥០-៧៤ឆ្នាំ ពីការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សជាទៀងទាត់។ *(អង្គការសុខភាពពិភពលោក)*

- កាលណាអ្នកចូលអាយុ៧៥ឆ្នាំហើយ អ្នកនឹងឈប់លែងបានទទួលលិខិតរំលឹក ឱ្យអ្នកអញ្ជើញទៅថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សទៀតហើយ។

- មិនមានភ័ស្តុតាងវិទ្យាសាស្ត្រណាដែលបង្ហាញថា ស្ត្រីអាយុលើសពី៧៥ឆ្នាំដែលចូលរួមក្នុងកម្មវិធីថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សដូចជាប្រជាជនឯទៀត នឹងបានទទួលនូវអត្ថប្រយោជន៍ល្អចំពោះសុខភាពច្រើនជាងគ្រោះថ្នាក់នោះទេ។

- យើងសូមណែនាំឱ្យអ្នកទៅជួបវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីពិភាក្សាពីអត្ថប្រយោជន៍នៃការបន្តថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស។

- ខណៈពេលដែលហានិភ័យនៃការវិវត្តទៅជាជំងឺមហារីកដោះកើនឡើងទៅតាមអាយុ ប្រសិនបើអ្នកសម្គាល់ឃើញមានការប្រែប្រួលមិនធម្មតានៅក្នុងដោះរបស់អ្នកដូចជាដុំសាច់ពក ការមានទឹករំអិលហូរចេញពីក្បាលដោះ ស្បែកមានការប្រែប្រួល ឬការឈឺចាប់ ថ្មីដែលមិនបាត់ទៅវិញនៅក្នុងដោះ សូមទៅជួបវេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់។

**សម្រាប់ព័ត៌មានបន្ថែម សូមហៅទូរស័ព្ទលេខ 13 20 50។**


**BreastScreen WA**

ទូរស័ព្ទ៖ 13 20 50

អ៊ីម៉េល៖ breastscreenwa@health.wa.gov.au

សេវាកម្មជាតិបញ្ជូនបន្ត www.relayservice.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងនិយាយ (TIS) 13 14 50


BreastScreen AUSTRALIA
A joint Australian, State and Territory Government Program

LIKE US ON facebook